[Return Address]
[Return Address]
[Return Address]
[Return Address]

Pennsylvania
Department of Human Services

[Client Address]
[Client Address]
[Client Address]
[Client Address]

# យើងខ្ញុំបានបញ្ចូលសំណុំបែបបទពាក្យសុំ ចុះឈ្មោះអ្នកបោះឆ្នោតជាមួយលិខិតនេះ ។

យើងខ្ញុំកំពុងផ្ញើជូនលោកអ្នកនូវពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតនេះ ដើម្បីធានាថាលោកអ្នកទទួលបានឱកាសចុះឈ្មោះបោះឆ្នោតនៅពេលលោកអ្នកមានទំនាក់ទំនងជាមួយក្រសួងសេវាកម្មពលរដ្ឋ ។ ច្បាប់ស្តីពីការចុះឈ្មោះអ្នកបោះឆ្នោតថ្នាក់ជាតិ (NVRA) តម្រូវឱ្យមានសេវាកម្មនេះ ។

ការដាក់ពាក្យសុំចុះឈ្មោះ ឬការបដិសេធមិនចុះឈ្មោះបោះឆ្នោត <u>នឹងមិនមាន</u>ផលប៉ះពាល់ដល់ចំនួនជំនួយដែលលោកអ្នកនឹងត្រូវបានផ្តល់ជូនដោយទីភ្នាក់ងារនេះឡើយ ។

**ប្រសិនបើលោកអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយតាមអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក ៖** លោកអ្នកមិនត្រូវការបំពេញពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះម្តងទៀតឡើយ ។ លោកអ្នកអាចពិនិត្យមើលការចុះឈ្មោះអ្នកបោះឆ្នោតតាមវិបសាយ www.VotesPA.com.

**ប្រសិនបើលោកអ្នកចង់ចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពកំណត់ត្រាចុះឈ្មោះបោះឆ្នោតរបស់អ្នក ដើម្បីបង្ហាញអំពីការផ្លាស់ប្តូរអាសយដ្ឋាន ឈ្មោះ ឬគណបក្ស ៖** លោកអ្នកត្រូវតែបំពេញព័ត៌មានដែលទាមទារ<u>ទាំងអស់</u>នៅក្នុងពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោត ហើយផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬប្រគល់ជូនពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតដែលបានបំពេញហើយទៅគណៈកម្មការរៀបចំការបោះឆ្នោតនៅខោនធីមូលដ្ឋានរបស់អ្នក (អាសយដ្ឋាននានាដែលបានចុះបញ្ជីនៅក្នុងពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោត) ឬលោកអ្នកអាចបញ្ជូនពាក្យសុំទៅការិយាល័យជំនួយនៅខោនធីមូលដ្ឋានរបស់អ្នក ។ ប្រសិនបើលោកអ្នកបញ្ជូនសំណុំបែបបទទៅការិយាល័យជំនួយនៅខោនធីរបស់អ្នកវិញនោះ ការិយាល័យដែលអ្នកចុះឈ្មោះ នឹងនៅតែរក្សាការសម្ងាត់ដដែល ។

## ដើម្បីចុះឈ្មោះបោះឆ្នោតបាន លោកអ្នកជាពលរដ្ឋអាមេរិក ។

**ប្រសិនបើលោកអ្នកត្រូវការជំនួយបំពេញពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោត** សូមទាក់ទងការិយាល័យជំនួយនៅខោនធីរបស់អ្នក ឬហៅទូរស័ព្ទលេខ 1-800-692-7462 (PA Relay Services 711 សម្រាប់បុគ្គលដែលមានបញ្ហាខាងស្តាប់) ។

ប្រសិនបើលោកអ្នកជឿជាក់ថា មាននរណាម្នាក់បានរំខានដល់សិទ្ធិរបស់អ្នកចំពោះការចុះឈ្មោះ ឬបដិសេធមិនចុះឈ្មោះបោះឆ្នោត សិទ្ធិរបស់អ្នកចំពោះសិទ្ធិឯកជនភាពក្នុងការសម្រេចថាតើត្រូវចុះឈ្មោះ ឬការដាក់ពាក្យសុំចុះឈ្មោះបោះឆ្នោត ឬសិទ្ធិជ្រើសរើសគណបក្សនយោបាយផ្ទាល់ខ្លួនរបស់អ្នក ឬចំណង់ចំណូលចិត្តខាងនយោបាយផ្សេងទៀតនោះ លោកអ្នកអាចដាក់ពាក្យបណ្តឹងទៅលេខាធិការសហគមន៍នៃក្រសួងរដ្ឋផេនស៊ីលវ៉ាន់នៀ តាមអាសយដ្ឋាន Secretary of the Commonwealth, Pennsylvania Department of State, 302 North Office Building, Harrisburg, PA 17120, ឬហៅទូរស័ព្ទទៅក្រសួងរដ្ឋតាមលេខទូរស័ព្ទឥតគិតថ្លៃ 1-877-VOTESPA (1-877-868-3772).